# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀងស្តីពីការព្យួរកិច្ចសន្យាការងារ

រោងចក្រ **យូហ្វី ថេរលើរ ខប ភើរេសិន** ដែលមានលោក LEE EHIEN JONG នាយករោងចក្រជាតំណាង ហៅកាត់ថា ភាគី (ក)។

**និង**

តំណាងកម្មករ-សហជីពរបស់រោងចក្រ **សួង សុខជាង** ហៅកាត់ថា ភាគី (ខ)។ ក្រោយពីប្រជុំពិភាក្សាគ្នារួចភាគីទាំងពីរបានព្រមព្រៀង និងឯកភាពគ្នាតាមប្រការ និងលក្ខខណ្ឌ ដូចខាងក្រោម:

**ប្រការ ១**.ភាគី(ក) នឹងរៀបចំព្យួរកិច្ចសន្យាការងាររបស់កម្មករ-និយោជិតចំនួន ១២៣នាក់ (ស្រី ១១២នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៨៥៣នាក់ (ស្រី ៧៣២នាក់) រយៈពេល ៦១ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ០១ ខែសីហា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០។

**ប្រការ ២**. ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ រោងចក្រផ្តល់ប្រាក់ឧបត្ថម្ភម្នាក់ៗ **៣០ដុល្លាអាមេរិក** ពីរោងចក្រ នឹងបូកបន្ថែម ៤០ ដុល្លារអាមេរិក ពីរដ្ឋាភិបាល សរុបទាំងអស់ចំនួន **៧០ ដុល្លារអាមេរិក** សម្រាប់កម្មករម្នាក់ៗ។

**ប្រការ ៣**. ភាគី(ក) ត្រូវបើកប្រាក់ព្យួរកិច្ចសន្យាការងារនេះនៅថ្ងៃទី០៩ **រៀងរាល់** ខែបន្ទាប់។

**ប្រការ ៤**. ភាគី(ខ) ត្រូវត្រឡប់ចូលធ្វើការងារវិញនៅ ថ្ងៃទី **០១** ខែ **តុលា** ឆ្នាំ**២០២០** ចំពោះអ្នកដែលមិនបានត្រឡប់ មកធ្វើការងារតាមកាលកំណត់នឹងត្រូវចាត់ទុកថាឈប់ឥតច្បាប់។

ភ្នំពេញ, ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០

| | |
|---|---|
| ហត្ថលេខា ភាគី (ខ) | ហត្ថលេខា ភាគី (ក) |
| សួង សុខជាង | DFI TAILOR CORPORATION |